# សាសនានិងពុទ្ធសាសនា

ដោយ៖ **បណ្ឌិត ភ្លាន់ ធុល**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា
វិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

មានអ្នកអាននិងអ្នកស្រាវជ្រាវជាច្រើនបានចោទសួរថា តើព្រះពុទ្ធសាសនាជា **សាសនា** ឬក៏ជា **ទស្សនវិជ្ជា**?

ចំណោទនេះខ្ញុំសូមធ្វើការស្រាវជ្រាវហើយបកស្រាយដូចខាងក្រោម៖

## ១- អំពីសាសនា

សាសនាជាគ្រឿងតាំងនៅជាអចិន្ត្រៃយ៍ដូចនយោបាយនៅក្នុងសង្គមដែរ។ ប្រវត្តិសាស្ត្រ បានកត់ត្រាពីសង្គមថា សង្គមមួយដែលមានមនុស្សមិនទាន់បានប្រតិបត្តិទម្រង់សាសនាណាមួយនៅឡើយនោះ ទោះជានៅសម័យបុព្វកាលក្តី។ ការសិក្សា ជាពិសេសដោយសង្គមវិទូ និង នរវិទូបង្ហាញឱ្យឃើញថា សាសនាគឺជាធាតុវប្បធម៌មូលដ្ឋានមួយ (a basic cultural element) របស់សង្គមៗ ដូច្នេះ សាសនាសមនឹងគេអះអាងដោយស្រួលថាគឺជាសង្គមនៅក្នុងកម្រិតអភិវឌ្ឍន៍ ផ្សេងៗ (various levels of development) ទោះនៅទីកន្លែងណា និងនៅពេលណាក៏ដោយ សុទ្ធតែមានជំនឿ និងការប្រតិបត្តិសាសនាមួយចំនួនជាមិនខាន។ រួមជាមួយនឹងលក្ខណៈមូលដ្ឋានផ្សេងៗទៀតនៃជីវិតសង្គម មានដូចជា **ភាសា** (language), **សិល្បៈ** (arts), **វិទ្យាសាស្ត្រ** (science), និង **បច្ចេកវិទ្យា** (technology) ជាដើម។ សាសនាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើមនុស្សម្នាក់ៗ ក៏ដូចជាទៅលើក្រុមមនុស្សដែលយើងហៅថា **សង្គម** នេះផងដែរ។ **តម្លៃ** (value) និង **ឥទ្ធិពល** (influence) របស់សាសនាទៅលើសង្គម បានបង្ហាញយ៉ាងច្បាស់លាស់ និងយ៉ាងមានប្រសិទ្ធភាពនៅក្នុងវគ្គខាងក្រោម៖

រួមជាមួយវិធីចរិកលក្ខណៈ (*characteristic*

*ways*) នៃការបង្កើតការរស់នៅ និង ការរស់នៅជាមួយគ្នា ដោយល្អប្រពៃ វប្បធម៌មនុស្សម្នាក់មានវិធីយល់ដឹងល្អៗ និងច្បាស់លាស់ ដទៃទៀត ចំពោះការ ប្រព្រឹត្ត, ការមានវេទនារម្មណ៍ ហើយ និងការប្រព្រឹត្ត ដែលយើងនិយមឱ្យឈ្មោះ ថា "**សាសនា**"។ តាមរយៈសាសនារបស់ពួក គេដែលសង្គមបានផ្តល់ឱ្យដល់ជីវិត មនុស្សនូវទំនាក់ទំនងគួរជាទីពេញចិត្ត និងមានន័យចំពោះពិភពលោកដែលមនុស្សកំពុងរស់នៅៗក្នុងនោះ។ ដោយសារស្ថិតនៅក្នុងលក្ខខណ្ឌសាសនានេះហើយ ទើបបានជាពួកគេសម្តែង គតិបណ្ឌិតល្អបំផុត (best wisdom) នៅក្នុងការប្រព្រឹត្តការងាររបស់មនុស្សនោះ។[1]

**សាសនា** បានជ្រួតជ្រាបយ៉ាងខ្លាំងចូលទៅក្នុងជីវិតសង្គម ដែលគ្មាននរណាម្នាក់ហ៊ាន បដិសេធពីវត្តមានរបស់សាសនានេះបានឡើយ។ អ្វីមួយដែលមនុស្សធ្វើចំពោះសាសនា ទោះ មិនចូលចិត្តក្តី ទោះស្អប់ក្តី ឬទោះព្រងើយកន្តើយក្តី ដែលអាចមានលទ្ធផលមកពីការអប់រំ (upbringing) ឬបទពិសោធន៍ផ្សេងៗ របស់គេនោះ ក៏គេមិនអាចមិនយកចិត្តទុកដាក់ចំពោះ សាសនានេះបានដែរ។ ទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី នេះក៏ព្រោះតែសាសនាជះឥទ្ធិ ពលយ៉ាងខ្លាំងក្លាមកលើជីវិតរបស់គេ មិនមែនមួយថ្ងៃប៉ុន្តែពេញមួយជីវិតតែម្តង។ នេះគឺជាការអះអាងរបស់លោកហ៊ូហ្វ(Mr. Houf) ដែលបានសរសេរថា **សាសនា** គឺជា "**មូលដ្ឋានប្រយោជន៍របស់មនុស្សដ៏សំខាន់បំផុតមួយក្នុងចំណោមមូលដ្ឋានប្រយោជន៍របស់មនុស្សដ៏សំខាន់បំផុតនានា និងជាផ្នែកស្ថិតស្ថេរមួយនៃជីវិត និងវប្បធម៌របស់មនុស្ស** (religion is one of the most basic of human interests and, a lastillg part of man's life and culture)"។ សង្គមវិទូយល់ស្របថា **សាសនា** "**ជាផ្នែក បញ្ចូលគ្នាមួយនៃបទពិសោធន៍របស់ មនុស្ស និងបង្ហាញពីនិរន្តរភាពគួរកត់ សំគាល់តាមរយៈពេលវេលា** (religion is an integrated part of mart's experience and shows remarkable continuity through time.)"។ សេចក្តីអះអាងនេះមាន ការគាំទ្រដូចខាងក្រោម ៖

សាសនាមិនអាចផ្តាច់ចេញពី**ជីវិតមនុស្ស** បានទេ។ វាជាការប្រត្តិកម្មនៃការៈទាំងមូល របស់មនុស្សចំពោះ

[៩] Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974, p 141

វត្ថុពិសិដ្ឋរបស់គេ។ នៅកម្រិតដ៏ប្រសើរបំផុតរបស់សាសនា ៗ ត្រូវបានគេចាប់អារម្មណ៍ និងយកមកគិត។ សាសនាត្រូវមានជីវិតឡើង។ សាសនា ត្រូវប្រែក្លាយខ្លួនឯងទៅជាអំពើ។ សាសនាមិនមែនជាផ្នែកមួយនៃជីវិតទេ (segment of life) ហើយសាសនាក៏មិន ទាក់ទងទៅនឹងពេលវេលា ឬទីកន្លែងណា មួយនោះដែរ។ សាសនា មិនគ្រាន់តែជា ពិធីសាសនា (ritual), ពិធី (ceremony), លទ្ធិ (doctrines), ឬព្រះវិហារ (church) នោះប៉ុណ្ណោះទេ តែកត្តាទាំងអស់នេះអាច ជាជំនួយក្នុងការជំរុញដល់សាសនា។ អ្នក ដឹកនាំពូជសាសន៍សាសនាធំៗ *(the great religious leaders of the race)* បាន និយាយ ពីសាសនាថា ជាជីវិតសម្ព័ន្ធមួយ (vital) ពោលគឺ បទពិសោធន៍ផ្ទាល់ខ្លួននេះឯង។

ប៉ុន្តែ តើសាសនាពិតជាមានតួនាទីសំខាន់អ្វីខ្លះនៅក្នុងជីវិតនិងសង្គម? តើសាសនាក្លាយ ទៅជាផ្នែកមួយនៃជីវិតសង្គមយ៉ាងដូចម្តេច? តើសាសនាមានមុខងារអ្វីខ្លះចំពោះមនុស្ស និង ចំពោះសង្គម? ខ្ញុំនឹងខិតខំព្យាយាមដោះស្រាយចំពោះចំណោទខាងលើនេះ។ ច្រើនជាងនេះទៀត គឺត្រូវពិភាក្សាទៅតាមបែប សាមញ្ញមួយតាមតែអាចធ្វើទៅបាន ចំពោះបញ្ហាសាសនា ដែលតាមធម្មតាវាគ្របដណ្តប់ទៅលើការសិក្សាទស្សនវិជ្ជាអំពីសាសនា (philosophical studies of religion) ហើយដែលតែងតែកើតមានជារឿយៗនៅក្នុងការជជែកវែកញែកខាងសាសនា (denominational debates)។ ទាំងអស់នេះ ជាបញ្ហា អំពី **អត្ថិភាព** (the existence) និង **ធម្មជាតិរបស់អាទិទេព** (nature of God), **ព្រលឹង** (soul) និង **អមតៈភាព** (immortality) និង **បញ្ហាអំពើបាប** (the problem of evil) បើតាម **សាហាខៀន** (*Sahakian*) និង **សាហាខៀន** (*Sahakian*) "គឺវាមានសារៈសំខាន់ដ៏លើសលុបក្នុងការសិក្សាទស្សនវិជ្ជាសាសនា" [2]។

ពាក្យ "**សាសនា** (religion)" មានន័យខុសៗគ្នាទៅតាមមនុស្ស។ នេះក៏ព្រោះតែមនុស្ស ម្នាក់ៗទាំងនោះមានបទ ពិសោធន៍សាសនាដោយឡែកៗ និងមាន វិធីបង្ហាញសាសនាផ្សេងៗ គ្នា។ មនុស្ស ដែលកើតមកនៅ**ទីរហោឋាន** (wilderness) ឬនៅ **តំបន់ព្រៃភ្នំ** អាចស្ងើចសរសើរពី**បរិស្ថានជុំវិញ** (surroundings) ខ្លួននិង ឈានដល់ការគោរព**ព្រលឹងអរូបី** (the unseen spirit) ដែលគេជឿថា ព្រលឹងទាំង នោះបានបង្កើត និងគ្រប់គ្រង

---

[២] Venancio B. Ardales, op. cit. p 142

ពិភពលោក (world) របស់គេ។ ជំនឿបែបនេះ គឺជា មូលដ្ឋាននៃទំរង់សាសនាបុរាណ ដែលគេ ស្គាល់រហូតដល់សព្វថ្ងៃនេះថាជា **ជំនឿវិញ្ញាណនិយម** (animism) នេះឯង។ សាសនានេះនៅតែមានមនុស្សមួយចំនួន ដែលមិនទាន់បានទទួលឥទ្ធិពលពីអរិយធម៌ ខ្ពង់ខ្ពស់គោរពប្រតិបត្តិនៅឡើយ។ ម្យ៉ាងវិញទៀត មនុស្ស ដែលបានរស់នៅៗក្នុងពិភពអរិយធម៌បង្ហាញជាច្រើនដង និងជាញឹកញយនូវការប៉ះទង្គិចជំនឿ, លទ្ធិ និងមតិយោបល់ផ្សេងៗ។ ឆ្លងតាមការ បង្ហាញទាំងនេះ ពួកគេឈានដល់ការយល់ដឹងពី **អាទិទេព** (God) ទៅតាម របៀបផ្សេងៗគ្នា។ មានអ្នកដែលរៀនអំពី អាទិទេពតាមរយៈ "ចម្ងល់ (the wonders" របស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផងដែរ។ អ្នកខ្លះទៀតឈានដល់ការយល់ដឹងពី អាទិទេពតាមរយៈ **សេចក្តីទុក្ខ** (suffering) ឬ **ការលំបាក** (difficulty) របស់ខ្លួន។ អ្នកខ្លះ ទៀត ត្រូវគេបង្រៀនអំពី **អាទិទេព** តាមរយៈ **វិហារ** (the church/mosque), វត្ត (monastery) ឬតាមរយៈអ្នកជំនឿនីមួយៗដែលមាន អារម្មណ៍ថាវាគឺជាទំនួលខុសត្រូវរបស់ពួកគេចំពោះភ័ស្តុតាងអាទិទេព។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏មានអ្នក មិន ដែលស្គាល់អាទិទេព ដោយសារ ការមើលស្រាល (ondifference) របស់ខ្លួន ឬ អរិភាពបើកចំហ (open hostility) ចំពោះ ជំនឿ និងការប្រតិបត្តិសាសនាសព្វ យ៉ាង ផងដែរ។ ទាំងអស់នេះជា អ្នកប្រឆាំង (anticlericals) និង **អទេវបុគ្គល**(atheists) ដែលឥរិយាបថរបស់ពួកគេ ចំពោះ **អាទិទេព** និងសាសនា កើតចេញមកពី "វិធីវិភាគហ្មត់ចត់របស់ពួកគេ ដែលនៅក្នុងនោះ ស្ថាប័នសាសនាបានដំណើរការ នៅក្នុងសង្គមទាំងនៅក្នុងប្រវត្តិសាស្ត្រដ៏ យូរលង់របស់គេ និងទាំងនៅក្នុងបច្ចុប្បន្ន កាលនេះ"។

សាសនា ដែលអ្នកជឿ និងប្រតិបត្តិ មានការយល់ដឹងយ៉ាងណានោះ បង្ហាញឱ្យ ឃើញតាមរយៈនិយមន័យ ផ្សេងៗគ្នា ដែលគេបានសរសេរ។ អ្នកអាន ដែលមានការរិះគន់នឹងរកឃើញថា និយមន័យទាំងនេះមានទំនោរបញ្ជាក់ពីអ្វីដែលមានចំពោះយើងជាលក្ខណៈបទពិសោធន៍សាសនា ដ៏លើសលុបនេះឯង។ និយមន័យខ្លះមាន បំណងផ្តោតទៅលើ **ធាតុបញ្ញា របស់ សាសនា** (the intellectual element of religion) ពោលគឺគ្មានអ្វីក្រៅពីជំនឿ (a set of beliefs) ដែលគេមានជំនឿ

(faith) ដ៏ច្រើនបំផុតនៅក្នុងនោះៗទេ។ ឯអ្នកផ្សេងទៀតសង្កត់ធ្ងន់ទៅលើ **វេទនារម្មណ៍** (the feeling) ឬ **ទិដ្ឋភាពរំជួលចិត្ត** (emotional aspect) ចំពោះសាសនា។ ឯចំពោះអ្នកផ្សេងក្រៅពីនេះច្រើនសង្កត់ធ្ងន់ទៅលើ **ផ្នែកឆន្ទៈ** (the volitional part) ចំពោះសាសនាទៅវិញ។

ការឱ្យនិយមន័យភាគច្រើនទទួលយកសាសនាថាជា **បញ្ហាជំនឿ** (matter of belief) ដោយហេតុនេះហើយបានជាគេនិយមទទួលស្គាល់សាសនាថាជា **ជំនឿលើអាទិទេព** (belief in God) ឬ **ការៈអធិធម្មជាតិ** (supernatural being) និង **ព្រលឹង** (any spiritual)។ មានឧទាហរណ៍ពីរដែលនិយាយពីប្រភេទនិយមន័យនេះ។ ឧទាហរណ៍មួយជារបស់ **វីលៀម ជែម** (William James) និងឧទាហរណ៍មួយទៀតជារបស់ **អ៊ីមៀល ឌឹកខេម** (Emile Durkheim)។ **ជែម**(Jame) និយាយថា "នៅក្នុងន័យទូលំទូលាយ និងទូទៅបំផុតដែលអាចធ្វើទៅបាន គេអាចនិយាយថា ជីវិតសាសនា (religious life) មានជំនឿថា មាន **បញ្ញាអាថ៌កំបាំង** (unseen order) ហើយនិងជំនឿថា[3] **មហាកុសល** (supreme good) របស់យើងស្ថិតនៅក្នុងការសម្របខ្លួនដោយសុខដុមរមនាចំពោះមហាកុសលនោះ។ **ជំនឿ** និង **ការសម្របខ្លួន** (adjustment) នេះគឺជាឥរិយាបថសាសនាទៅលើ **ព្រលឹង** (the soul)"។ ចំពោះលោក **ឌឹកខែម** យល់ឃើញថា សាសនាគឺជា "**ប្រព័ន្ធ ជំនឿនិងការប្រតិបត្តិរួមគ្នាមួយ** (a unified system of beliefs and practice) ដែលទាក់ទងទៅនឹង **វត្ថុពិសិដ្ឋ** (sacred things) មានន័យថា វត្ថុដែលរៀបចំដាច់ដោយឡែក និងជំនឿ និងការប្រតិបត្តិហាមឃាត់ (forbidden beliefs and practices) ដែលរួមបញ្ចូលទៅជាសហគមន៍សីលធម៌តែមួយ (one single moral community) ដែលគេឱ្យឈ្មោះថា ព្រះវិហារ (church) ឬវត្ត (pagoda) ពោលគឺអ្នកទាំងឡាយណាដែលផ្សារភ្ជាប់ខ្លួនទៅនឹងជំនឿនិងការប្រតិបត្តិទាំងនោះ"។ និយមន័យរបស់ **ឌឹកខែម** ប្រហែលជាយកជាការបានល្អជាងគេចំពោះខ្លឹមសាររបស់ "សាសនា" នៅត្រង់ថា ខ្លឹមសារសាសនាមានប្រភពមកពីពាក្យឡាតាំងថា Religare ដែលមានន័យថា "ដើម្បីបញ្ចូលជាមួយគ្នា (to bind together)។"

និយមន័យដូចតទៅនេះសង្កត់ធ្ងន់លើ ទិដ្ឋភាពរំជួលចិត្តរបស់សាសនា (the

[៣] Venancio B. Ardales, op. cit. p 143

emotional aspect of religion) ៖ "ខ្លឹមសារ សាសនា (the essence of religion) មាន នៅក្នុងវេទនារម្មណ៍ ដែលពឹងផ្អែកទាំង ស្រុង ទៅលើ ***ចក្រវាឡ*** (the universe) ឬ ទៅលើ ***អាទិទេព***។ សាសនា គឺជាការ គោរព អំណាចដ៏ខ្ពស់មកពី គំនិត ត្រូវការ (the sense of need)។ សាសនាគឺជា ជំនឿរបស់ មនុស្សទៅលើឬឋានុភាពមួយ ដែលទៅហួសពីខ្លួនឯង ដែលតាមរយៈនេះ មនុស្សស្វែងរកដើម្បី បំពេញតម្រូវខាង អារម្មណ៍ (emotional needs) និង ដើម្បី ទទួលបាននូវ ***ស្ថេរភាពជីវិត*** (stability of life) ដែល គេត្រូវសម្តែងបង្ហាញ តាមរយៈ សកម្មភាពគោរពបូជា និងបម្រើ។

និយមន័យមួយដែលសង្កត់ធ្ងន់ទៅ លើ ***ជាតុឆន្ទៈ*** (the volitional element) ក៏ ដូចជា ***ធម្មជាតិសាសនាឆន្ទៈនិយម*** (the voluntaristic nature of religion) ដែល ***វ. ខ. បាវើ*** (W. C. Bower) បានផ្តល់ឱ្យ និយាយថា ៖ សាសនាគឺជាទិដ្ឋភាពកែសម្រួលមួយក្នុងបំណោមទិដ្ឋភាពកែសម្រួលនានារបស់ មនុស្ស ចំពោះបរិស្ថានរួមរបស់គេ។ សាសនា គឺជាការសម្តែងឆន្ទៈដ៏ខ្ពស់បំផុត ***ដើម្បីរស់, ដើម្បីមានជីវិត***, និង ***ដើម្បីមាន សាសនា*** យ៉ាងច្រើនក្រៃលែង។ ទិដ្ឋភាព សំខាន់នៃដំណើរការកែសម្រួលនេះ គឺនៅ ហួសពី ការឈោងដល់របស់មនុស្ស និង ក្រុមនានាឆ្ពោះទៅរកគោល បំណងដ៏មាន តម្លៃ (worthful ends) ដែលមនុស្សរស់នៅ ដោយសារគោលបំណងនេះ។ សាសនា គឺជាទិដ្ឋភាពខំប្រឹងប្រែងដ៏ខ្ពស់បំផុតចំពោះ ជីវិត។ ដូច្នេះ សាសនាក្លាយទៅជា ឥរិយាបថ មួយឆ្ពោះទៅរក តថភាព បរិស្ថាន (the environing reality) ដែល ទាក់ទងទៅនឹង គំនិត ពឹងផ្អែកមួយលើ សាសនា ជាការប៉ុនប៉ង ដើម្បីទាញយក ជំនួយពីសាសនាតាមរយៈ ការបង្កើត ទំនាក់ទំនងផ្ទាល់ខ្លួន ជាមួយ សាសនា ហើយនិងការប្រើបទពិសោធន៍, វប្បធម៌, អង្គការ (organization), ហើយនិង ទំនៀម ទម្លាប់សង្គមក្នុងការប៉ុនប៉ង ដើម្បីថែរក្សា ធនធានទាំងនេះ។ សាសនា ផ្តោតទៅលើ ឥរិយាបថហ្មត់ចត់ស៊ីជម្រៅ ឆ្ពោះទៅរកតថភាពទាំងនេះថាជាអ្នក កំណត់ជោគវាសនា (a Determiner of Destilly) មួយ។ នៅក្នុងទម្រង់កាន់តែខ្ពស់ និងកាន់តែ ផ្សងព្រេងរបស់សាសនា ការជម្រុញឆ្ពោះ ទៅរកការរស់នៅដ៏សម្បូរបែបនេះសន្មត់ ថា ទិដ្ឋភាពធ្វើពិសោធន៍ចាំបាច់ជាមួយនឹង លទ្ធភាពជីវិតអតថភាព (the unrealized possibilities of life)។[៤]

---

[៤] Venancio B. Ardales, op. cit. p 144

និយមន័យខ្លះមានលក្ខណៈគ្រប់គ្រាន់ជាងនិយមន័យផ្សេងទៀត ដែលបានបង្ហាញជូននៅខាងលើ ដោយហេតុថា វាគ្របដណ្តប់មិនត្រឹមតែទៅលើលក្ខណៈសាសនាមួយនោះទេ ប៉ុន្តែ វាគ្របដណ្តប់ទៅលើលក្ខណៈសាសនាជាច្រើន។ ដូចលោក ខ. ឃីកផាទ្រិក (C. Kirkpatrick) យល់ថា "សាសនាគឺជាគំរូវប្បធម៌មួយ (culture pattern) ដែលពឹងផ្អែកទៅលើទំនាក់ទំនងជាមួយ ***អធិធម្មជាតិ*** (the Supernatural) ឬ***ភាពអស្ចារ្យ***(the Extraordinary) ដទៃៗទៀតដែលបាន យល់ដឹងដោយមនុស្សពិសេសៗ ដែល មានការពាក់ព័ន្ធជាមួយ។ នៅក្នុងទម្រង់ ល្អបរិសុទ្ធរបស់ខ្លួន សាសនាទាក់ទងទៅ នឹង៖

ក- សេចក្តីរំភើបចិត្តចំពោះការគោរព (the emotion of reverence)

ខ- ជំនឿទៅលើឬទ្ធានុភាពអាថ៌ កំបាំង (mysterious powers) ដែល បាន ធ្វើបដិរូបកម្ម[5] (personify) ជាធម្មតា ហើយដែលមិនអាចគ្រប់គ្រងដោយមធ្យោបាយធម្មតាបាន។

គ- អាកប្បកិរិយា មិនបង្ខិតបង្ខំ (non-coercive behavior) ដែល នាំ មនុស្សឱ្យមាន ទំនាក់ទំនងជាមួយឬទ្ធានុភាពទាំងនេះ ដែលជានិច្ចកាលច្រើនស្ថិតនៅជាមួយនឹង ជំនួយវត្ថុវប្បធម៌ (the aid of culture objects) ។

ការវិភាគរិះគន់ពីគ្រប់និយមន័យសាសនាទាំងអស់នឹងបង្ហាញឱ្យឃើញថាមាន ***កត្តាបី*** ដែលបិតនៅជុំវិញការបកស្រាយពាក្យដែលជាប់ទាក់ទង។ កត្តាទាំងបីនោះរួមមាន

ក- ជំនឿទៅលើ**កម្លាំងអច្ឆរិយបុគ្គល** (ឬកម្លាំងនានា) ដែលអាច ឬមិនអាចធ្វើបដិរូបកម្មបាន។

ខ- តម្រូវការចំពោះ ***តម្លៃសម្ភារៈ*** និង ***តម្លៃផ្លូវចិត្ត*** ជាក់លាក់។

គ- ការកែសម្រួលលក្ខណៈនានាចំពោះ ***កម្លាំងអច្ឆរិយបុគ្គល*** (the superhu-man power) ក្នុងគោលបំណងការ ពារតម្លៃទាំងនេះ[6]។

## ២- អំពីពុទ្ធសាសនា

បញ្ញត្តិ "***ព្រះពុទ្ធសាសនា*** (= ព្រះពុទ្ធ+ សាសនា)" ឬជាភាសាអង់គ្លេសថា

---

[5] ការធ្វើអ្វីមួយដែលគ្មានរូបរាងឱ្យមានរូបរាង មានចិត្ត គំនិតជាមនុស្ស

[6] Venancio B. Ardales, op. cit. p 145

"Buddhism (= Buddha + ism)"។ ព្រះពុទ្ធ (Buddha) គឺលោកអ្នកត្រាស់ដឹងធម៌ដែលកំបាំង ដូចយ៉ាងអរិយសច្ច ៤ ជាដើម រហូតដល់មគ្គផលនិព្វាន, ឬលោកអ្នកភ្ញាក់រឭកគឺមានសតិសម្បជញ្ញៈសព្វកាល, ឬលោកអ្នករីកពេញទីដូចជាផ្កាឈូកដែលរីកគ្រប់ស្រទាប់ គឺមានព្រះហឫទ័យរីកដោយអំណាចនៃបរិសុទ្ធិ ព្រោះកម្ចាត់កិលេសអស់ហើយ (ព្រះសម្មាសម្ពុទ្ធ ដែលជាអ្នកបង្កើតពុទ្ធសាសនា)[7]។ ឯពាក្យថា "សាសនា" តាមពិតទៅពាក្យនេះត្រូវនឹងពាក្យអង់គ្លេសថា "religion" ប៉ុន្តែនៅក្នុងបរិបទព្រះពុទ្ធសសនាដែលសរសេរជាភាសាអង់គ្លេសថា "Buddhism" ដោយមានបស្ទឹមបទថា "ism" ត្រូវនឹង ពាក្យខ្មែរថា "លទ្ធិ ឬនិយម" ដូចជា Confucianism លទ្ធិខុងជឺឬខុងជឺ និយម, Taoism សាសនាតាវឬលទ្ធិតាវ ឬតាវ និយម, materialism លទ្ធិរូបជាតុ ឬរូប ជាតុនិយម ជាដើម។ ដូចនេះ បស្ទឹមបទ ដែលថា "លទ្ធិ, និយម, ឬism" ចង់សំដៅ ដល់និកាយ, ជំនឿ, មនោគមវិជ្ជា, ទ្រឹស្តី, ឬគំនិតទស្សន វិជ្ជា អំពីអ្វីមួយរបស់អ្នក ណាម្នាក់ដែលគេអាចហៅមកជាសាសនាក៏បាន។ តាមរយៈសំណេរជាភាសាអង់គ្លេស "Buddhism" អ្នកស្រាវជ្រាវខ្លះអាច ហៅថា ពុទ្ធលទ្ធិ ឬលទ្ធិពុទ្ធនិយម ដូចជា អក្សរសិល្ប៍ពុទ្ធនិយមជាដើម ក៏បាន។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ពុទ្ធសាសនិក ជនខ្លួនឯងភាគច្រើនបំផុត ហៅ "Budd-hism" នេះថា ជាពុទ្ធសាសនាដែរ ដែលគេ មិនគួរច្រឡំជាមួយនឹង អ៊ីស្លាមសាសនា, គ្រិស្តសាសនា ដែល មានទ្រឹស្តី, គោល-ការណ៍អប់រំ, និងគោលបំណង ដោយ ឡែកពីព្រះពុទ្ធសាសនានោះ ឡើយ។ ខាង ក្រោមនេះគឺ ជាខ្លឹមសារស៊ីជម្រៅបន្ថែម ទៀតនៃ ព្រះពុទ្ធសាសនា៖

ចំពោះចំណោទដែលថាតើព្រះពុទ្ធសាសនាជាសាសនាដែរឬទេនោះ បើគេធ្វើការសិក្សា ស្រាវជ្រាវឱ្យដល់ជម្រៅនៃព្រះពុទ្ធសាសនា ព្រះពុទ្ធសាសនាគ្មានគឺអ្វីក្រៅអំពី **អរិយសច្ច** (the Noble Truth) ពោលគឺទុក្ខ, ហេតុនៃទុក្ខ, សេចក្តីរលត់ទុក្ខ, ផ្លូវដើរឱ្យដល់សេចក្តីរលត់ទុក្ខនោះឡើយ[8]។

[7] ជួនណាត, វចនានុក្រមខ្មែរអេឡិចត្រូនិច, រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ ពុទ្ធ

[8] ខៀវ ជុំ, ជីវិតសន្តិភាព, ភ្នំពេញ លង្កាព្រះកុសុមារាម, ព.ស. ២៥១២ គ.ស.១៩៧០, ទំព័រ ១២

តាមពិត ពុទ្ធសាសនាមិនមែនមាន ត្រឹមតែ **ទស្សនវិជ្ជា** (a Philosophy), ជា **សាសនា** (a religion) ឬក៏ជា **មាគ៌ាជីវិត** (a way of life)ប៉ុណ្ណោះនោះទេ គឺមានច្រើន ហួសពី៣នេះទៅទៀត។

មនុស្សខុសៗគ្នារស់នៅក្នុងសម័យកាលខុសៗគ្នា និងនៅក្នុងទីកន្លែងខុសៗគ្នា ឱ្យស្វាក និងការបកស្រាយខុសៗគ្នា ចំពោះព្រះពុទ្ធសាសនា។ ចំពោះមនុស្សមួយចំនួន ព្រះពុទ្ធសាសនា គ្រាន់តែជា **ការប្រតិបត្តិអបិយជំនឿ** (a mass of superstitious practices) ប៉ុណ្ណោះ។ ចំពោះមនុស្សមួយក្រុមទៀតយល់ថា ព្រះពុទ្ធសាសនាអាចជាស្ពានងាយស្រួលសម្រាប់ប្រើប្រាស់ដើម្បី **ប្រយោជន៍លោកិយ** (temporal gains)។ ចំពោះមនុស្សមួយក្រុមផ្សេងទៀត ព្រះពុទ្ធ សាសនា គ្រាន់តែជា **ការសម្ដែងពីភាពចាស់ទុំ** (old fashioned)។ ឯចំពោះមនុស្សក្រុមផ្ទុយពីនេះយល់ថា ព្រះពុទ្ធ សាសនាមានសារៈសំខាន់ជា **ប្រព័ន្ធគំនិត** (system of thought) សម្រាប់តែបញ្ញវន្តប៉ុណ្ណោះ។ ចំពោះអ្នកដទៃទៀតយល់ថា ព្រះពុទ្ធសាសនាគឺជា **របកគំហើញវិទ្យាសាស្ត្រ** (a scientific discovery)។ប៉ុន្តែចំពោះពុទ្ធសាសនិកជនដែលស្រលាញ់ និងជឿស៊ុបវិញយល់ ថា ព្រះពុទ្ធសាសនា **ធ្វើឱ្យជីវិតរបស់គេមានន័យពេញលេញ**។

បញ្ញវន្តខ្លះយល់ឃើញថាព្រះពុទ្ធសាសនាជា **ផលិតផលនៃបរិស្ថានឥណ្ឌា** ឬជា **ការរីកដុះដាលពីប្រភេទបង្រៀនសាសនាឥណ្ឌាមួយប្រភេទទៀត**។ ព្រះពុទ្ធសាសនាគឺគ្មានអ្វីក្រៅពី **អរិយសច្ច**នោះ។ វាជាការចាប់យកបញ្ញា ចំពោះ **តថភាព** (reality)។ ការយល់ច្បាស់របស់ព្រះ ពុទ្ធ ចំពោះ **បញ្ហាសាកល** (universal problems) មិនមែនបានមកតាមរយៈដំណើរមានហេតុផល ឬបញ្ញាសុទ្ធសាធ នោះទេ ប៉ុន្តែតាមរយៈ**អភិវឌ្ឍន៍** និង **បន្សុទ្ធិកម្ម ខួរក្បាល** ( mental development and purification) ។ ដំហរ បញ្ញារត់ស្របទៅតាមឥរិយាបថវិទ្យាសាស្ត្រគឺពិត ជាធ្វើឱ្យព្រះពុទ្ធប្លែកដាច់ពីក្នុង ចំណោមគ្រូប្រដៅសាសនានានា នៅគ្រប់ សម័យកាល។ ជា ការពិតណាស់ គំរូខ្ពស់ នៃការស្វែងរក បញ្ញា ហើយនិងការព្យាយាមប្រកបដោយក្រមសីលធម៌ដែលកំពុងមាននៅពេលនោះ នៅក្នុងប្រទេសឥណ្ឌា គឺជាលក្ខខណ្ឌចម្បងសម្រាប់ការ កើតឡើងវិញនូវពន្លឺព្រះធម៌ពីភាពងងឹតនៃអវិជ្ជា។ អភិវឌ្ឍន៍

ទស្សនវិជ្ជា និងសាសនាអស់ ពេលរាប់ពាន់ឆ្នាំបានបន្សល់ទុកនៅលើដីបញ្ញា (intellectual soil) របស់ឥណ្ឌា ដែលជាកន្លែងផ្ទុកនូវគំនិត និងឧត្តមភាពដ៏មានជីជាតិនិងសម្បូរបែប ដែលបង្កើតបានជាបរិស្ថានលទ្ធភាព ដ៏ល្អបំផុតដែលគ្រាប់ពូជព្រះធម៌អាចធ្លាក់ចូលទៅទីនោះ។ ប្រទេសក្រិក, ចិន, អេហ្ស៊ីប, និង បាប៊ីឡូន (Babylonia) ដែលធ្លាប់មានគំនិតខ្ពស់ត្រដែត ក៏មិនបានទៅដល់គុណភាពចក្ខុវិស័យ (quality of vision) ដូចព្រៃ និងអ្នកប្រាជ្ញឥណ្ឌា ដែលអាស្រ័យនៅនឹងភ្នំដូច្នេះដែរ។ ពន្លកត្រាស់ដឹងដែលបានចាប់កំណើតឡើង ដូចគ្រាប់ពូជដុះស្លាប (winged seed) ពីថ្ពាលដ៏ឆ្ងាយ, ពីពិភពនានានៅក្នុងកាលនិងលំហ ដ៏ឆ្ងាយជាអនេកពីការត្រាស់ដឹងរបស់ យើង ពោលគឺពន្លកត្រាស់ដឹងនេះឯងដែលបានរកឃើញការរីកចម្រើន និងអភិវឌ្ឍន៍នៅឥណ្ឌា ប៉ែកឥសាន។ ពន្លកត្រាស់ដឹងនេះបានរកឃើញការសម្ដែងរបស់ខ្លួនដោយបរិបូរទៅលើបទ ពិសោធន៍របស់មនុស្ស ពោលគឺ ព្រះពុទ្ធគោត្តមនេះឯង។ ប្រភពពុទ្ធសាសនាដើមទាំងស្រុងគឺជាបទពិសោធន៍ ដែលគេឱ្យឈ្មោះថា "**ការត្រាស់ដឹង** (enlightenment)"។ ជាមួយនឹងបទពិសោធន៍ត្រាស់ដឹងនេះ ព្រះពុទ្ធទ្រង់ចាប់ផ្ដើមការបង្រៀនរបស់ព្រះអង្គ មិនមែនជាមួយនឹងជំនឿ ឬទេវកថាតាមបែបផ្ដាច់មុខ (dogmatic beliefs) ណាមួយនោះទេ ប៉ុន្តែជាមួយនឹង បទពិសោធន៍សាកលនិងមានសុពល ដែលព្រះអង្គបានផ្ដល់ឱ្យដល់ពិភពលោកជា **សច្ចភាពសាកល**។

ដូច្នេះ និយមន័យពិតរបស់ព្រះពុទ្ធសាសនាគឺ **អរិយសច្ច** នេះឯង។ សូមរំលឹកថា ព្រះពុទ្ធមិនមែនបង្រៀនចេញអំពីទ្រឹស្ដីនោះទេ។ ជានិច្ចកាលព្រះអង្គ តែងបង្រៀនចេញពី **ទស្សនៈប្រតិបត្តិ** (practical standpoint) ដោយផ្អែកទៅលើ **ការយល់ដឹង** របស់ព្រះអង្គ ពោលគឺ **ការត្រាស់ដឹង** (Enlightenment) ហើយ និង **ការស្គាល់សច្ចភាពច្បាស់** (realization of the Truth) របស់ព្រះអង្គ។

ព្រះពុទ្ធសាសនាបានចាប់ផ្ដើមជាមួយនឹង **សច្ចភាព** ដែលមានរូបរាងអស់ពេលជាង ២៥០០ឆ្នាំមកហើយនៅក្នុងឋានៈជាមនុស្សគោត្តម (the person of Gautama) ពោលគឺព្រះពុទ្ធនេះឯង។ នៅពេលព្រះពុទ្ធផ្សព្វផ្សាយការទូន្មានរបស់

ព្រះអង្គ បំណងរបស់ព្រះអង្គមិនមែន ដើម្បីអភិវឌ្ឍ **បញ្ញត្តិអត្ត** (the concept of self) នៅក្នុងស្មារតីរបស់មនុស្ស ហើយ និង បង្កើតមហិច្ឆតាច្រើនទៅលើ **ជីវិត អមតៈ** (eternal life) ហើយនិង **កាមារម្មណ៍** (sense-pleasure) នោះទេ។ ផ្ទុយទៅវិញ បំណងរបស់ព្រះ គឺចង់ ចង្អុលប្រាប់ពី **ភាពឥតន័យនៃជីវិត លោកិយ** (the futility of the worldly life) របស់យើង ហើយនិងចង់ បង្ហាញពី **ផ្លូវប្រតិបត្តិដ៏ត្រឹមត្រូវ** ចំពោះការរំដោះ ទុក្ខភ័យដែលព្រះអង្គ បានរកឃើញ។

ការបង្រៀនដើមរបស់ព្រះពុទ្ធផ្តើម ចេញពី **ធម្មជាតិជីវិតពិត** (the true nature of life) និងពិភពលោក។ ទោះជាយ៉ាងណា ក៏ដោយ ក៏មានការខុសប្លែក គ្នាមួយដែល គេត្រូវតែ បង្កើតឡើងរវាង ការបង្រៀន ដើមរបស់ព្រះពុទ្ធ (ដែលជា រឿយៗគេតែង ហៅថា **ព្រះធម៌ ឬ ពុទ្ធ វចនៈ**)ហើយនិង **សាសនា** ដែលបាន អភិវឌ្ឍដោយ ផ្អែក លើការបង្រៀនរបស់ព្រះអង្គ។

ការបង្រៀនរបស់ព្រះពុទ្ធមិនមែន គ្រាន់តែជាការចាប់ផ្តើមសាសនាមួយប៉ុណ្ណោះទេ ក៏ប៉ុន្តែការបង្រៀននេះក៏បាន ជម្រុញឱ្យចេញជា **រូបរាងអរិយធម៌** (the blossoming of a whole civilization) ទាំងមូល ទៀតផង។ ការបង្រៀនទាំងនេះ បានក្លាយ ទៅជាកម្លាំងអារ្យធម៌ ដ៏មួយ (a great civilizing force) ដែលជម្រុញតាម រយៈ ប្រវត្តិសាស្ត្រជាច្រើនទូវវប្បធម៌ និង ជាតិ។ តាមពិត ព្រះពុទ្ធសាសនាបាន ក្លាយទៅជា អរិយធម៌ដ៏ធំបំផុតមួយក្នុងចំណោមអរិយ ធម៌ធំៗនានាដែលពិភព លោកធ្លាប់បាន ដឹង។ ព្រះពុទ្ធសាសនា មានប្រវត្តិសមិទ្ធិផល ដ៏អស្ចារ្យនៅក្នុង វិស័យអក្សរសិល្ប៍, សិល្បៈ, ទស្សនវិជ្ជា, ចិត្តវិជ្ជា, សីលវិជ្ជា, ស្ថាបត្យកម្ម និងវប្បធម៌។ អស់ពេលរាប់ សតវត្សមក ហើយស្ថាប័នអប់រំសង្គម រាប់ មិនអស់ត្រូវបានបង្កើតឡើងនៅតាម បណ្តាជាតិនានា ដែលសុទ្ធតែឧទ្ទិសចំពោះ ការ បង្រៀនរបស់ព្រះពុទ្ធទាំងអស់។ ប្រវត្តិ ព្រះពុទ្ធសាសនាត្រូវគេរៀបចំចងក្រងទៅ ជាអក្សរមាសក្នុងភាពជាបងប្អូន និង សុធន្ទៈ។ ជំនឿនិងការប្រតិបត្តិសាសនា ត្រូវរំលេចចូលទៅក្នុងមាគ៌ាជីវិតខាងសាសនា ប្រតិបត្តិ, វិទ្យាសាស្ត្រ និង ហេតុផល សម្រាប់ការអភិវឌ្ឍន៍ផ្លូវចិត្ត (spiritual development) ចាប់តាំងពីថ្ងៃ ព្រះពុទ្ធ សម្តែងពីការបង្រៀនរបស់ព្រះអង្គ ហើយ បានដឹងច្បាស់ពីគោលបំណងពិត ហើយ

និងខ្លឹមសារជីវិតនិង សាសនា[៩]។

## សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការស្រាវជ្រាវនិងបក ស្រាយដូចខាងលើ **សាសនា** មានន័យ ខុសប្លែកពី **ព្រះពុទ្ធសាសនា**។ សាសនា គឺជាចំណីស្មារតីរបស់មនុស្សចំពោះ កម្លាំងក្រៅខ្លួនពោល គឺជា ជំនឿរបស់មនុស្សចំពោះ **អធិធម្មជាតិ** ឬ **អាទិទេព**។ ក្នុងន័យនេះ មនុស្សដ៏ច្រើននៅក្នុងពិភពលោក ត្រូវការសាសនាជា ប្រចាំនៅក្នុងជីវិតរស់នៅរបស់ពួកគេ។ ពួកគេត្រូវការការគោរពបូជា បន់ស្រន់សុំសេចក្ដីសុខនិងសេចក្ដី ចម្រើន។ ចំណែក ឯព្រះពុទ្ធសាសនាវិញ មិនជឿលើកម្លាំង ក្រៅខ្លួនទេ គឺជឿលើ កម្លាំងខំប្រឹងប្រែងរបស់ខ្លួន ជឿលើអំពើ របស់ខ្លួន "អ្នកណាធ្វើ អ្នកនោះបាន," "អ្នកណាសាបព្រោះ គ្រាប់ពូជអ្វី អ្នកនោះនឹងទទួលបានផលពីគ្រាប់ពូជនោះ" ដូច ពុទ្ធភាសិតថា "ខ្លួនទី ពឹងខ្លួន" បញ្ជាក់ស្រាប់។ **ព្រះពុទ្ធសាសនា** មានបំណងចង់ ដឹកនាំអ្នកជឿឱ្យទទួលយក **សាសនា** ដោយឆ្លងកាត់តាម **ការគិត សនិទាន** (rational thinking) ក្នុងការស្វែង រក **សច្ចភាព** ក្នុងជំនឿចំពោះ **អាទិទេព**។ ពីព្រោះការ មានជំនឿទៅលើអាទិទេព គឺជា ការធ្វើ ដំណើរនៅក្នុងទីងងឹត គឺជាជំនឿ អាថ៌កំបាំង ដែលគ្រាន់តែជាការដឹងតាមរយៈស្ដាប់គ្រូប្រដៅសាសនា ឬអាននិង យល់ដឹងទៅតាមគម្ពីរសាសនា ដែលគ្រូ ប្រដៅបាន តាក់តែងឡើងដោយផ្សារភ្ជាប់ **អព្ភូតហេតុធម្មជាតិអស្ចារ្យ** គ្មានភស្ដុតាង អ្វីឱ្យច្បាស់លាស់ក្នុង ការបញ្ជាក់ថា ពិតជា មានអាទិទេពមែន ហើយព្រះអង្គពិតជា អាចជួយមនុស្សឱ្យរួចផុតចាកទុក្ខបាននោះ ឡើយ។ ជំនឿសាសនាធ្វើឱ្យមនុស្ស ពិការភ្នែកបាត់បង់ការគិតពិចារណាហេតុផល ដែលនាំឱ្យដឹកនាំជីវិតទៅរកគ្រោះថ្នាក់។

អ្នកដែលមិនបានសិក្សារៀនសូត្រពីសាសនា នឹងមិនស្គាល់សាសនាច្បាស់ច្បាស់ទេ។ ពួកគេងាយនឹងទទួលយកសាសនាដែលទាក់ទងទៅនឹងជំនឿគ្មានភស្ដុតាងខ្លាំងទៅតាមសរីរាង្គ ឥន្ទ្រិយរបស់ពួកគេ។ អ្នកជឿបែបនេះងាយនឹងជឿស៊ុបក្នុងសាសនា ហើយពួកគេមានអារម្មណ៍ប្រាកដប្រជាថា ខ្លួនកំពុងទទួលបានជំនឿពិតគួរឱ្យទុក្ខចិត្តបំផុតមួយបើទោះជាមិនមានផលជា ភស្ដុតាងក៏ដោយ។

---

[៩] K. Sri Dhammananda, *What the Buddhists believe*, 5th ed., Taiwan, 1993, p51-53

សម្តេច **ពិន សែម** មានព្រះថេរដីការថា "**ពុទ្ធសាសនា** អ្វីដែលមាន **ហេតុ** មិនមាន **ផល** គឺបដិសេធន៍ អត់ទទួលយកបានទេ" សម្តេចបន្តថា "មានមនុស្សដែលខ្វះបញ្ញា ដែលមិនបានសិក្សារៀនសូត្រគឺប្រកាន់ ជាប់លើជំនឿដែលមាន **ហេតុ** មិនមាន **ផល** នេះឯង"។

សម័យសព្វថ្ងៃ ជំនឿសាសនាកើតមានច្រើនណាស់ ដែលគ្រូប្រដៅសាសនាបានបង្កើតឡើង ហើយមានហួតសសើរពីបារមីស័ក្តិសិទ្ធទៀតផង។ តែទោះជាយ៉ាងណា តាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្ន នៅក្នុងជីវភាពប្រចាំថ្ងៃ គេសង្កេតឃើញថា គ្រូស្រោចទឹកនៅតែជា គ្រូស្រោចទឹក, គ្រូទាយធុតឆាប់សព្វថ្ងៃ នៅតែជាគ្រូទាយ, គ្រូដោះអំពើអាបធ្មប់ នៅតែជាគ្រូដោះ អំពើអាបធ្មប់, ព្រឹត្តិការណ៍សោកនាដកម្មរញ្ជួយដីស៊ូណាមិ, ខ្យល់ព្យុះ, ជំងឺកូវីដ១៩ មនុស្សត្រូវស្លាប់រាប់ម៉ឺនរាប់សែននាក់ សាសនាជំនឿក្រៅខ្លួនដែលមានតែ ***ហេតុឥតផល*** ហើយដែលល្បីថាពូកែសក្តិសិទ្ធ មិនដឹងជាជួយមនុស្សបានអ្វីខ្លះ អ្នកស្លាប់នៅតែស្លាប់ អ្នកក្រលំបាកវេទនានៅតែក្រលំបាកវេទនា ឯអ្នកបន់ស្រន់នៅតែបន់ស្រន់ ដូចជាមិនឃើញកម្លាំងណាមួយអាចជួយស្រោចស្រង់បានសោះ។ ហើយម្យ៉ាងវិញទៀត **សាសនា** និង **មេប្រដៅសាសនា** ក៏កាន់មានច្រើន តែ **ជម្មោះសាសនា** ក៏កាន់តែមានច្រើនទៅតាមនោះដែរ។ បើសង្កេតមើលពីគោលបំណងនិងគោលដៅរបស់អ្នកបង្កើតនិងអ្នកដើរតាមសាសនា គឺចង់ឱ្យជីវិតរស់នៅមានវិបុលភាព ហើយគោលដៅសុទ្ធតែឆ្ពោះទៅរកទីវិបុលភាពទាំងអស់ ប៉ុន្តែ សួរថាតើហេតុអ្វីបានជាមាន ការបំបែកទៅជានិកាយសាសនាផ្សេងៗចេញពីប្រភពសាសនាមេដើម? នេះមកពីអ្នកដើរតាមសាសនាមេដើមបែកគំនិតនៅក្នុងជំនឿសាសនាមេដើមរបស់ខ្លួនដែលនាំទៅរកការបំបែកទៅជានិកាយផ្សេងៗ។ នៅក្នុងទ្រឹស្តីបដិសំយោគ ការបែកគំនិតបំបែកទៅជានិកាយផ្សេងៗបង្ហាញឱ្យឃើញពីគំនិតនៅក្នុង **ជំនឿខុសគ្នា** គឺ **គំនិតខុសគ្នា** នេះហើយជា **ប្រភពជម្លោះ**។ ហេតុនេះ គេអាចនឹងចោទសួរថា សាសនាជាប្រភពនៃសេចក្តីសុខ តើវាអាចជាប្រភពជម្លោះដែរទេ? តើការបន់ស្រន់ទៅលើកម្លាំងក្រៅខ្លួននេះមានសច្ចភាពទេ? ជាគំនិតសនិទាន ឱ្យតែមានភ្លើងគឺពិតជាមានផ្សែង តែនេះមានតែភ្លើង

ឥតផ្សែង មានតែហេតុឥតផលមានតែ
ជំនឿ មានតែការបន់ស្រន់ តែឥតឃើញវត្ថុ
ស័ក្តិសិទ្ធិណាឱ្យអ្វីសោះឡើយ។ ឃើញតែ
ការខំប្រឹងប្រែងដោយកម្លាំងខ្លួនឯងដើរ
មុនជាដរាប។ តែទោះជាយ៉ាងណាក៏
ដោយ គេមិនអាចកាត់ផ្តាច់ ឬបំបែក
ជំនឿក្រៅខ្លួនចេញពីមនុស្សបានទេ
"អាគមន៍ផ្សំអាយុ" ទោះ ជាវិទ្យាសាស្ត្រ
រីកចម្រើនយ៉ាងណាក៏ដោយ។ អ្នកជឿ
សាសនាគួរប្រកាន់ទៅតាមគោលគំនិត
ដូនតាថា "ជួយខ្លួនឯងជា មុនសិនទើបព្រះ
ជួយជាក្រោយ ឬក៏ថាព្រះជួយតែអ្នក
ដែលខំធ្វើ ខំរៀន ខំគិត ហើយនិងខំរកតែ
ប៉ុណ្ណោះ"។

## គន្ថនិទ្ទេស

### I- ស្នាដៃនិពន្ធជាភាសាខ្មែរ

១- ខៀវ ជុំ, *ជីវិតសន្តិភាព*, ភ្នំពេញ លង្កា ព្រះ កុសុមារាម, ព.ស. ២៥១៤ គ.ស. ១៩៧០

២- ជួនណាត, *វចនានុក្រមខ្មែរអេឡិចត្រូ និច,* រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធ សាសនបណ្ឌិត្យ, ២០០៨


## II- ស្នាដៃនិពន្ធជាភាសាអង់គ្លេស


1- K. Sri Dhammananda, *What the Buddhists believe,* 5th ed., Taiwan, 1993

2- Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974